# ព្រះរាជាណាចក្រកម្ពុជា

**សាលាឧទ្ធរណ៍ភ្នំពេញ** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **************

លេខៈ ៣៨១/០៣.៥.២០១២

សាលដីកា

លេខៈ ៩៣ក្រIIIស/២៥.១១.២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរៈរកស៊ី កើត និងរស់នៅ ភូមិចំបក់ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ឃុំខ្លួនថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ មានមេធាវីការពារលោក [redacted] វិបុល។

<u>ជាប់ចោទពីបទៈ</u> រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចំបក់ដង្គំ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នួន ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ បច្ចុប្បន្នរស់នៅ [redacted] ឃុំចំបក់ ស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ។

## ៦ដំណើររឿងមានដូចតទៅ៖

នៅយប់ថ្ងៃទី១៨ខែមករា ឆ្នាំ២០១០ វេលាម៉ោង២២ និង៣០នាទី នៅលើផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] នួន ស្ថិតនៅ ភូមិចំបក់ដង្គុំ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឈ្មោះ [redacted] ម៉ៅ បានលបឡើងទៅលើផ្ទះក្នុងខណៈដែលប្តីរបស់ជនរងគ្រោះមិននៅផ្ទះ ពន្លត់ចង្កៀងនៅលើផ្ទះ រួចបើកមុងចូលទៅដេកក្នុងមុងជាមួយ [redacted] នួន ដែលកំពុងដេកលក់ជាមួយកូនតូចម្នាក់ បន្លំធ្វើជាប្តីរបស់ជនរងគ្រោះ រំលោភបានសម្រេចម្តង ហើយរត់ចុះទៅផ្ទះបាត់ទៅ ដោយបន្សល់ទុកនូវស្បែកជើងមួយគូ នៅនឹងកាំជណ្តើរផ្ទះជនរងគ្រោះ លុះដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ដោយមានបណ្តឹងរបស់ជនរងគ្រោះ, ឈ្មោះ [redacted] ម៉ៅ ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងបញ្ជូនមកសាលាដំបូងខេត្តកំពង់ស្ពឺតែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៤ (យ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសឈ្មោះ [redacted] ម៉ៅ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ របរកសិ៍ កើតនៅ ភូមិចំបក់ដង្គុំ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ [redacted] ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទោសពីមុនគ្មាន ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់, (ឃុំខ្លួនថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ លេខខ្លួន៥០)។

ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទ រំលោភសេពសន្ថវៈ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅ ភូមិចំបក់ដង្គុំ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

២- វត្ថុតាងមានស្បែកជើងផ្ទាត់មួយគូ លេខ១០ ពណ៌ខៀវ ត្រូវរិបអូស និងបំផ្លាញចោល។

៣- សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវប្តឹងទាស់ និងផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់លោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤ (យ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ របស់លោកស្រី [redacted] ម៉េងអ៊ាម ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤ (យ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ គ្រង់ចំណុចទី១ នៃសេចក្តីសម្រេច ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ឆ្លើយថា នៅយប់កើតហេតុ ខ្លួនពិតជាបានលបឡើងទៅលើផ្ទះជនរងគ្រោះ ឈ្មោះ [redacted] នួន នៅពេលដែលប្តីនាងមិននៅ ហើយបានរួមរ័ក្សនឹងនាងប្រាកដមែន ប៉ុន្តែប្រព្រឹត្តដោយមានការព្រមព្រៀង។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នួន ឆ្លើយថា នៅពេលកើតហេតុនេះ ឈ្មោះ [redacted] ម៉ៅ ពិតជាបានរួមរ័ក្សជាមួយខ្លួនមែន ប៉ុន្តែ ដោយមានការព្រមព្រៀងប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងនេះឃើញថាជនជាប់ចោទបានទទួលសារភាពថា បានរួមភេទជាមួយជនរងគ្រោះមែន ដោយមានការព្រមព្រៀង មិនមែនចាប់បង្ខំទេ, តាមចម្លើយជនរងគ្រោះ មុនដំបូងថាជនជាប់ចោទរំលោភ ប៉ុន្តែក្រោយមកថាមានការព្រមព្រៀងជាមួយជនជាប់ចោទ ដោយបងប្អូនឃើញទើបខ្លួនប្តឹង, ហើយនាពេលសវនាការជនជាប់ចោទ និងជនរងគ្រោះបានមកចូលរួមសវនាការ ហើយជនជាប់ចោទបានឆ្លើយថាពិតជាបានរួមភេទជាមួយជនរងគ្រោះមែន ប៉ុន្តែមិនមានការបង្ខិតបង្ខំទេ ហើយជនរងគ្រោះក៏បានដកពាក្យបណ្តឹងវិញដែរ ក្នុងករណីនេះសូមសភាព្រហ្មទណ្ឌពិចារណា និងសម្រេច តាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីខ្លួនត្រូវបានសាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៥ឆ្នាំ ពីបទរំលោភសេពសន្ថវៈ ហើយក្រោយពីស្តាប់ការសួរដេញដោលក្នុងសវនាការបញ្ជាក់ថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការទេ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នួន បានបញ្ជាក់ថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ វេលាម៉ោង២២ និង៣០នាទីយប់ កូនក្តីខ្លួនឈ្មោះ [redacted] ម៉ៅ បានឡើងទៅលើផ្ទះឈ្មោះ [redacted] នួន ដើម្បីរួមភេទ ហើយការរួមភេទនេះកូនក្តីខ្លួន ក៏ដូចជាជនរងគ្រោះ គឺកើតឡើងដោយការព្រមព្រៀងគ្នា ព្រោះដើមបណ្តឹងនិយាយថា នៅពេលថ្ងៃពួកគាត់និយាយត្រូវរ៉ូវគ្នា យប់ហ្នឹងកូនក្តីខ្លួននឹងឡើងទៅផ្ទះ [redacted] នួន, ហើយពេលកូនក្តីទៅដល់ ឈ្មោះ [redacted] នួន មិនមែនដេកលក់ដូចចម្លើយនៅសាលាដំបូងទេ ហើយការដែលគាត់ឆ្លើយដោយសារតែធ្វើឲ្យប្តីអស់ចិត្ត ហើយតាមគាត់ គាត់មិនប្តឹងទេ ព្រោះគាត់ស្រលាញ់គ្នាពីមុនមក។ យើងឃើញថា នៅថ្ងៃកើតហេតុ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ប៉ុន្តែក្រោយហ្នឹង២ថ្ងៃបានមានបណ្តឹងប្តឹងមកកូនក្តីខ្លួន, ឃើញថា មិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា២៣៩ ស្តីពីការរំលោភសេពសន្ថវៈទេ ការរួមភេទនេះ គឺការកើតឡើងដោយការស្ម័គ្រចិត្ត ដូចនេះសូមលោកប្រធានមេត្តាពិចារណា សម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងសូមឲ្យដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាព។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍
## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់លោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ របស់លោកស្រី ហុក ម៉េងអ៊ាម ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ[redacted]ម៉ៅ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៧៦ និង៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. កាលពីរាត្រី វេលាម៉ោង២២កន្លះ នៃថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ មានអំពើរំលោភសេពសន្ថវៈមួយបានកើតឡើងលើនារីរងគ្រោះឈ្មោះ [redacted] នួន ដែលកំពុងដេកលក់នៅក្នុងមុងលើផ្ទះ, ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ម៉ៅ។

៤. តាមចម្លើយជនជាប់ចោទថា នៅយប់កើតហេតុ ខ្លួនពិតជាបានលបឡើងទៅលើផ្ទះជនរងគ្រោះឈ្មោះ [redacted] នួន នៅពេលដែលប្តីនាងមិននៅ ហើយបានរួមរ័ក្សនឹងនាងប្រាកដមែន ប៉ុន្តែប្រព្រឹត្តដោយមានការព្រមព្រៀង។

- នៅសាលាដំបូង ជនជាប់ចោទថា នៅពេលនោះនាង [redacted] នួន កំពុងដេកលក់ជាមួយកូននៅក្នុងមុង ហើយខ្លួនបានរួមរ័ក្សមែន។

៥. តាមចម្លើយនារីរងគ្រោះថា នៅថ្ងៃកើតហេតុនោះ ខ្លួនកំពុងដេកលក់ជាមួយកូនតូចក្នុងមុង ស្រាប់តែមានមនុស្សម្នាក់សង្កត់ខ្លួនជាប់ រើពុំរួច ស្រែកមិនចេញ ដោយគេខ្ទប់មាត់ជាប់ ហើយរំលោភខ្លួនបានសម្រេច ទើបគេថយចេញ។ នៅយប់នោះ ពេលប្តីខ្លួនត្រឡប់មកផ្ទះវិញ ខ្លួនមិនបានប្រាប់ទេ, លុះព្រឹកឡើងទើបខ្លួនប្រាប់ ហើយក៏នាំគ្នាទៅប្តឹងសមត្ថកិច្ច។

- តាមចម្លើយនៅសវនាការសាលាឧទ្ធរណ៍នារី [redacted] នួន ថា នៅពេលកើតហេតុនេះ ឈ្មោះ [redacted] ម៉ៅ ពិតជាបានរួមរ័ក្សជាមួយខ្លួនមែន ប៉ុន្តែ ដោយមានការព្រមព្រៀងប្រាកដមែន។

៦- តាមចម្លើយសាក្សីឈ្មោះ[redacted] រី ថា នៅយប់នោះខ្លួនឮនារី [redacted] នួន ស្រែកថា ជួយផងៗ អ្នកណាចាប់ខ្ញុំ, ខ្លួនចុះទៅមើល ឃើញមនុស្សម្នាក់រត់ចេញពីផ្ទះ [redacted] នួន។

៧. ដោយផ្អែកតាមចម្លើយនារីរងគ្រោះ និងចម្លើយសាក្សី ដែលបានឆ្លើយនៅសវនាការសាលាដំបូងខេត្តកំពង់ស្ពឺ អាចកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ពិតជាបានលបលួចឡើងទៅលើផ្ទះជនរងគ្រោះ ហើយបង្ខំរំលោភជនរងគ្រោះ ដែលកំពុងដេកលក់ រហូតបានសម្រេចប្រាកដមែន។

ដូច្នេះ ចម្លើយនារីរងគ្រោះនៅសវនាការសាលាឧទ្ធរណ៍នេះ គ្រាន់តែជាចម្លើយជួយដោះបន្ទុកជាក្រោយប៉ុណ្ណោះ មិនអាចចាត់ថា ជាការត្រឹមត្រូវឡើយ។ តែទោះជាយ៉ាងណា ក៏អាចចាត់ថា នារីរងគ្រោះព្រមលោះលាអនុគ្រោះដែរ។

៨. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចំបក់ជង្គុំ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

តែដោយជនរងគ្រោះ បានចូលមកឆ្លើយបញ្ជាក់ ដោយអះអាងថា ពេលនោះពិតជាមានការរួមភេទមែន ប៉ុន្តែ ជាករណីកើតឡើងដោយមានការព្រមព្រៀងពីខ្លួនដែរ។

ដូច្នេះ គួរពិចារណា តាមមាត្រា ១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ។

៩. សាលក្រមព្រហ្មទណ្ឌលេខ ៣៤ (ឃ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចការអនុវត្តទោសនៅចំណុចទី១ របស់ជនជាប់ចោទ គួរកែប្រែ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់លោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ របស់លោកស្រី [redacted] ម៉េងអ៊ាម ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៤ (ឃ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការ លើកលែងតែការអនុវត្តទោស ដែលចែងក្នុងចំណុចទី១ របស់ជនជាប់ចោទ ត្រូវកែប្រែថា:

« ឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៅ អនុវត្តទោសនៅក្នុងពន្ធនាគារ ចំនួន ០៣ឆ្នាំ ០៦ខែ (បីឆ្នាំប្រាំមួយខែ) ឯទោសសល់ សម្រេចព្យួរ តាមមាត្រា១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ »

ក្រៅពីនេះ តម្កល់ទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ និងនារីរងគ្រោះឈ្មោះ [redacted]នួន, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា:[redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា:[redacted] |

---

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី 04 ខែ 06 ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**